# ចំណាប់អារម្មណ៍

## ឯកឧត្តម តាវ សេងហួរ ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស
## អនុប្រធានទី១ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ និងជា
## ប្រធានគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ
## ក្នុងពិធី "គម្រប់ខួប២០ឆ្នាំនៃការបង្កើតអង្គការការីតាសកម្ពុជា
## និងពិធីបើកកិច្ចប្រជុំប្រចាំឆ្នាំអង្គការការីតាសអាស៊ី"

នៅសណ្ឋាគារភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

*សូមគោរព :*

- *លោកជំទាវបណ្ឌិត* ***ម៉ែន សំអន*** *ឧបនាយករដ្ឋមន្ត្រី ប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់របស់* ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់*
- *លោកស្រី* ***លេសលីអាន ណាយ*** (Lesley Aune Kuight) *អគ្គលេខាធិការអង្គការការីតាសអន្តរជាតិ*
- *លោក* ***អ៊ីវុន អាមប្រូយ*** (Yvon Ambroise) *ប្រធានការីតាសអាស៊ី*
- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរាជរដ្ឋាភិបាលកម្ពុជា*
- *ឯកឧត្តម លោកជំទាវ គណៈអភិបាលខេត្ត ប្រធានក្រុមប្រឹក្សាខេត្ត នៃរាជធានី ខេត្តគោលដៅទាំង០៩*
- *ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី តំណាងប្រទេសផ្តល់ជំនួយ ដៃគូរអភិវឌ្ឍន៍ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិការនៃអង្គពិធី ជាទីគោរពរាប់អាន !*

ថ្ងៃនេះ តាងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ) ដែលមានឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ជាប្រធាន ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមក្នុងពិធី **គម្រប់ខួប២០ឆ្នាំនៃការបង្កើតអង្គការការីតាសកម្ពុជា និងពិធីបើកកិច្ចប្រជុំប្រចាំឆ្នាំអង្គការការីតាសអាស៊ី** (The Caritas Asia Forum)។ នេះជាលើកទីមួយហើយដែលអង្គការការីតាសកម្ពុជា បានប្រារព្ធពិធីគម្រប់ខួបរបស់ខ្លួនចាប់តាំងពីអង្គការនេះត្រូវបង្កើតឡើងវិញនាឆ្នាំ១៩៩០មក ហើយក៏ជាលើកទីមួយផងដែរ ដែលអង្គការការីតាសអាស៊ីបានបើកកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការប្រារព្ធពិធីនាឱកាសនេះ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់លោកជំទាវបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ពីការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយបណ្តាដៃគូរអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ វិស័យឯកជន និងសង្គមស៊ីវិល ពិសេសអង្គការការីតាសកម្ពុជា សំដៅអភិវឌ្ឍលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសកាត់បន្ថយភាពក្រីក្រនៅព្រះរាជាណាចក្រកម្ពុជាស្របតាមយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

*លោកជំទាវបណ្ឌិតឧបនាយករដ្ឋមន្ត្រី ប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន !*

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការស្តារ អភិវឌ្ឍន៍ និងទប់ទល់នូវវិបត្តិកលយុគហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកល បានបង្កហានិភ័យគម្រាមកំហែងដល់សមិទ្ធផលជាផ្លែផ្កានៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលសម្រេចបាននាពេលកន្លងមក។ ប៉ុន្តែទោះជាយ៉ាងណា រាជរដ្ឋាភិបាលបានគិតគូរយ៉ាងច្បាស់លាស់សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងឡាយ ដោយបានដាក់ចេញ និងអនុវត្តក្នុងស្មារតីសកម្ម គ្រប់គ្រងនូវវិធានការ គោលនយោបាយគន្លឹះៗ ដើម្បីទប់ទល់ និងសម្រាលនូវបច្ច័យអាក្រក់ដែលបណ្តាលមកពីវិបត្តិទាំងនេះ។ រាជរដ្ឋាភិបាល ប្រឹងប្រែងក្តាប់ឱ្យបានជាប់នូវជីពចរសេដ្ឋកិច្ចជាតិ និងការធានាឱ្យបាននូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមួយ ដែលមានលក្ខណៈគត់មត់ មានភាពអំណោយផលសម្រាប់សេដ្ឋកិច្ច ពិសេសគឺការធានានូវលំនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ដូចប្រសាសន៍របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលបានថ្លែងក្នុងវេទិកា **កិច្ចសហប្រតិបត្តិការកម្ពុជាលើកទី៣** នាថ្ងៃៗនេះថា **"យើងត្រូវធានាឱ្យប្រជាជនមានអង្ករច្រកឆ្នាំង"**។ ទោះបីរាជរដ្ឋាភិបាលបានសម្រេចសមិទ្ធផលជាច្រើនក៏ដោយ ក៏រាជរដ្ឋាភិបាលនៅមានបញ្ហាប្រឈមដែលត្រូវជំនះដល់កិច្ចអភិវឌ្ឍ នោះគឺការកាត់បន្ថយភាពក្រីក្រជាងមួយភាគរយក្នុងមួយឆ្នាំ ស្របតាមបាវចនា **"សមធមិ"** នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា។ នោះមានន័យថា ដើម្បីសម្រេចឱ្យបានលទ្ធផលតាមការគ្រោងទុក រាជរដ្ឋាភិបាលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ បណ្តាអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងសង្គមស៊ីវិលផ្សេងៗទៀត។

*លោកជំទាវបណ្ឌិតឧបនាយករដ្ឋមន្ត្រី ប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន*

ជាក់ស្តែង តាមរយៈរបាយការណ៍របស់លោក **គីម រតនា** នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា ក្នុងរយៈពេល២០ឆ្នាំ (១៩៩០-២០១០) មកនេះ បានបង្ហាញថា អង្គការការីតាសកម្ពុជាបានបំពេញបេសកកម្មជាច្រើនក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាល ដែលបានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាលើគម្រោងសំខាន់ៗ ដូចជា ការលើកកម្ពស់សន្តិសុខស្បៀងនិងអាហាររូបត្ថម្ភ, កសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធជនបទ, សុខភាពភ្នែក, សុខភាពសហគមន៍, សុខភាពផ្លូវចិត្ត, ថែទាំអ្នកផ្ទុកមេរោគអេដស៍, សុខភាពទណ្ឌិត, បណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនក្រីក្រ និងការឆ្លើយតបនិងត្រៀមបង្ការគ្រោះមហន្តរាយផ្សេងៗ ដោយបានសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នមួយចំនួន ដូចជា ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ជាដើម។ បន្ថែមលើនេះ អង្គការការីតាសកម្ពុជាបានសហការជាមួយអង្គការអន្តរជាតិ ដូចជា អង្គការ WFP, Oxfam, WVC, LWS, Mary

Knoll, CRS, ACR និង UN agencies និងអង្គការជាតិ រួមមាន ៖ អង្គការ CCC, NGO Forum, ADHOC, LICADHO, S.P, HOPE, CEDAC និងអង្គការ FRIEND ជាដើម ។

ដោយឡែក ចំពោះកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ) អង្គការការីតាសកម្ពុជា បានរៀបចំវេទិកាកសិករថ្នាក់ជាតិស្តីពី *"រួមគ្នាស្វែងយល់ពីបម្រែបម្រួលអាកាសធាតុ ដើម្បីកសិកម្មប្រកបដោយនិរន្តរភាព"* ហើយនៅពេលថ្មីៗនេះ អង្គការការីតាសបានផ្តល់ស្បៀងសង្គ្រោះជូនជនរងគ្រោះដោយទឹកជំនន់ ទឹកភ្លៀង និងខ្យល់ព្យុះកេតសាណានៅក្នុងឃុំ២៦ ស្រុកចំនួន០៥នៃខេត្តកំពង់ធំ ដែលមានគ្រួសារសរុបចំនួន ៥ ៦៨៥គ្រួសារ, វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល និងកសិករគំរូ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការចែកអំណោយដល់ប្រជាពលរដ្ឋទីទាល់ក្រចំនួន ៣៨២គ្រួសារ នៅឃុំសំរោងលើ និងឃុំឪឡោក ស្រុកអង្គស្នួល ខេត្តកណ្តាល ជាដើម ។

ខ្ញុំសង្ឃឹមថា កិច្ចសហប្រតិបត្តិការរវាងអង្គការការីតាស ពិសេសអង្គការការីតាសកម្ពុជានឹងបន្តសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួង ស្ថាប័នជាតំណាង និងអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីចូលរួមចំណែកក្នុងជំនួយមនុស្សធម៌ និងការអភិវឌ្ឍន៍ លើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

*លោកជំទាវបណ្ឌិតឧបនាយករដ្ឋមន្ត្រី ប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដ៏ស្មោះដល់ថ្នាក់ដឹកនាំអង្គការការីតាសអន្តរជាតិប្រទេសផ្តល់ជំនួយ និងថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិកអង្គការការីតាសកម្ពុជាទាំងអស់ ដែលបានខិតខំបំពេញការងារជាច្រើនប្រកបដោយជោគជ័យ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវបណ្ឌិត **ឧបនាយករដ្ឋមន្ត្រី** ប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសូមព្រះអង្គ៨ទិស និងបារមីដែលគង់នៅសំពៅត្រៃលោក ត្រៃលក្ខណ៍ សូមប្រសិទ្ធពរជ័យជូនលោកជំទាវបណ្ឌិត និងក្រុមគ្រួសារ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីអាក់ខាន ។

សូមគោរពជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ប្រកបតែនឹងសេចក្តីសុខ សុខភាពល្អ និងសុភមង្គលជានិច្ចនិរន្ត ។

**សូមអរគុណ !**